ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពត

-សំណុំរឿងព្រហ្មទណ្ឌលេខ ៩៩ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២
-សំណុំរឿងស៊ើបសួរលេខ ២៩ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២
-សំណុំរឿងជំនុំជម្រះលេខ ២៩៨ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២
-សាលក្រមលេខ ៥៤៩ "ច" ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០២២

សាលក្រមព្រហ្មទណ្ឌ

ក្នុងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងខេត្តកំពត

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការសាលាដំបូងខេត្តកំពត នៅថ្ងៃទី២២ ខែវិច្ឆិកាឆ្នាំ២០២២ វេលាម៉ោង០២ រសៀល ដែលមានសមាសភាពដូចតទៅ:

ចៅក្រមជំនុំជម្រះ

លោកស្រី [redacted] ជាចៅក្រមសាលាដំបូងខេត្តកំពត

តំណាងអយ្យការ

លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពត

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពត

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៩៩ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ២០២២ ដែលមានៈ

១-ជនជាប់ចោទឈ្មោះ [redacted] ចាន់រ៉ាត់ ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរកម្មករសំណង់ ទីកន្លែងកំណើត[redacted] ខេត្តកំពត ទីលំនៅមុនពេលឃាត់ខ្លួន ភូមិក្រសាំងមានជ័យ ឃុំដូនយ៉ុយ ស្រុកឈូក ខេត្តកំពត ឪពុកឈ្មោះ [redacted] សឿន (ស្លាប់) ម្តាយឈ្មោះ [redacted] សារ៉ាត់ (រស់) នៅលីវ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន មាន ធ្លាប់ជាប់ពន្ធនាគារ ចំនួនពីរឆ្នាំ ពីបទ ជួញដូរ នូវសារធាតុញៀនខុសច្បាប់ និងប្រើប្រាស់គ្រឿងញៀន។ (ក្នុងឃុំ)

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១០៣/២២ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២ ។

២-ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ហៅ ខ្វី ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរកសិករ ទីកន្លែងកំណើត[redacted] ខេត្តកំពត ទីលំនៅមុនពេលឃាត់ខ្លួន ភូមិតាមុំ ឃុំបានៀវ ស្រុកឈូក ខេត្តកំពត ឪពុកឈ្មោះ [redacted] នឿន (រស់) ម្តាយឈ្មោះ [redacted] រិទ្ធី (រស់) ពោះម៉ាយ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន ។ (ក្នុងឃុំ)

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៨៨/២២ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ ។

៣-ជនជាប់ចោទឈ្មោះ [redacted] រតនៈ ហៅ យី ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរនិស្សិត ទីកន្លែងកំណើត[redacted] ខេត្តកំពត ទីលំនៅបច្ចុប្បន្ន ភូមិសត្វពង ឃុំសត្វពង ស្រុកឈូក ខេត្តកំពត ឪពុកឈ្មោះ [redacted] យូយ៉ាំង (រស់) ម្តាយឈ្មោះ [redacted] គីមថូ (រស់) នៅលីវ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន ។ (ក្រៅឃុំ)

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩០/២២ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ និងដោះលែងឱ្យនៅក្រៅឃុំតាមដីកាបង្គាប់ឱ្យដោះលែងលេខ ៧៤/២២ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ ។

៤-ជនជាប់ចោទឈ្មោះ [redacted]ថ្វី ហៅ អាស្វា ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរនិស្សិត ទីកន្លែងកំណើត[redacted] ខេត្តកំពត ទីលំនៅបច្ចុប្បន្នភូមិព្រៃគគីរ ឃុំដងទង់ ស្រុកដងទង់ ខេត្តកំពត ឪពុកឈ្មោះ [redacted] តិ (រស់) ម្តាយឈ្មោះ [redacted] ម៉ៅ (រស់) នៅលីវ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន ។ (ក្រៅឃុំ)

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១០៥/២២ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២ និងដោះលែងឱ្យនៅក្រៅឃុំតាមដីកាបង្គាប់ឱ្យដោះលែងលេខ ៧៨/២២ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ ។

៥-ជនជាប់ចោទឈ្មោះ [redacted]រ៉ែន ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរជាងផ្សារដែក ទីកន្លែងកំណើត[redacted] ខេត្តកំពត ទីលំនៅបច្ចុប្បន្នភូមិព្រៃគគីរ ឃុំដងទង់ ស្រុកដងទង់ ខេត្តកំពត ឪពុកឈ្មោះ [redacted] ប្រុស (ស្លាប់) ម្តាយឈ្មោះ [redacted]ធា (រស់) នៅលីវ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន ។ (ក្រៅឃុំ)

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១០៧/២២ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២ និងដោះលែងឱ្យនៅក្រៅឃុំតាមដីកាបង្គាប់ឱ្យដោះលែងលេខ ៧៦/២២ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ ។

៦-ជនជាប់ចោទឈ្មោះ [redacted] លិ ភេទប្រុស កើតថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៣ អាយុ១៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរបើកឡានដឹកខោអាវលក់ ទីកន្លែងកំណើត[redacted] ខេត្តកំពត ទីលំនៅបច្ចុប្បន្ន ភូមិដំណាក់ទ្រព្យខាងត្បូង ឃុំក្រាំងស្នាយ ស្រុកឈូក ខេត្តកំពត ឪពុកឈ្មោ[redacted] ចាន់ (រស់) ម្តាយឈ្មោះ [redacted] ចាន់ធី (រស់) នៅលីវ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន ។ (ក្រៅឃុំ)

ដីកាសម្រេចមិនឃុំខ្លួនលេខ ៦៤ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២ ។

៧-ជនជាប់ចោទឈ្មោះ [redacted] វន្នី ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរនិស្សិត ទីកន្លែងកំណើត[redacted] ខេត្តកំពត ទីលំនៅបច្ចុប្បន្នភូមិអង្គរពោក ឃុំដំណាក់សុក្រំ ស្រុកដងទង់ ខេត្តកំពត ឪពុកឈ្មោះ [redacted] រ៉ាត់ (រស់) ម្តាយឈ្មោះ [redacted]សុផាត (រស់) នៅលីវ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន ។ (ក្រៅឃុំ)

ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ១១០/២២ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ ។

៨-ជនជាប់ចោទឈ្មោះ [redacted] មិថុនា ភេទប្រុស កើតថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០០ អាយុ១៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរកសិករ ទីកន្លែងកំណើតនៅ[redacted] ខេត្តកំពត ទីលំនៅបច្ចុប្បន្ន ភូមិបើន ឃុំល្អាង ស្រុកដងទង់ ខេត្តកំពត ឪពុកឈ្មោះ [redacted] វ៉ែត (រស់) ម្តាយឈ្មោះ [redacted]គីម (រស់) នៅលីវ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន ។ (ក្រៅឃុំ)

ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ១០៩/២២ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ ។

៩-ជនជាប់ចោទឈ្មោះ [redacted]សាន់ ភេទប្រុស កើតថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៣ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរកសិករ ទីកន្លែងកំណើតនៅ[redacted] ខេត្តកំពត ទីលំនៅបច្ចុប្បន្ន ភូមិព្រៃបែន ឃុំសត្វពង ស្រុកឈូក ខេត្តកំពត ឪពុកឈ្មោះ [redacted] ជើង (រស់) ម្តាយឈ្មោះ [redacted]ហ៊ាន់ (រស់) នៅលីវ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន ។ (ក្រៅឃុំ)

ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ១០៨/២២ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ ។

ជាប់ចោទពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស (ប្រើដាវ) ប្រព្រឹត្តនៅ ភូមិត្រពាំងតាមាល ឃុំដំណាក់សុក្រំ ស្រុកដងទង់ ខេត្តកំពត កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

-មានរលោក [redacted] ជាមេធាវីការពារក្តីជនជាប់ចោទឈ្មោះ [redacted] រតនៈ ។

Scanned with CamScanner

-ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីមុិច ភេទប្រុស អាយុ ៣៦ឆ្នាំ មានអាសយដ្ឋាន ភូមិក្រសាំងមានជ័យ ឃុំដូនយ៉ុយ ស្រុកឈូក ខេត្តកំពត ។

-ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីម៉ើល ភេទប្រុស អាយុ ៣៤ឆ្នាំ មានអាសយដ្ឋាន ភូមិក្រសាំងមានជ័យ ឃុំដូនយ៉ុយ ស្រុកឈូក ខេត្តកំពត ។

អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២ ស្ថិតនៅភូមិ ត្រពាំងតាមាល ឃុំដំណាក់សុក្រំ ស្រុកដងទង់ ខេត្តកំពត មានករណី ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស (ស្នាក់កាប់ជនរងគ្រោះ) មួយកើតឡើងដែលបង្កឡើងដោយជនជាប់ចោទ ១.ឈ្មោះ [redacted] វុទ្ធី ហៅ ខ្វី ភេទប្រុស អាយុ២៣ឆ្នាំ ២.ឈ្មោះ [redacted] រតនៈ ហៅ យី ភេទប្រុស អាយុ២១ឆ្នាំ ៣.ឈ្មោះ [redacted]រិទ្ធី ហៅ ស្វា ភេទប្រុស អាយុ២១ឆ្នាំ ៤.ឈ្មោះ [redacted]រ៉ែន ភេទប្រុស អាយុ២២ឆ្នាំ ៥.ឈ្មោះ [redacted] វន្នី ភេទប្រុស អាយុ១៩ឆ្នាំ ៦.ឈ្មោះ [redacted]ចាន់រ៉ាត់ ភេទប្រុស អាយុ២៥ឆ្នាំ ៧.ឈ្មោះ [redacted]លិ ភេទប្រុស អាយុ១៩ឆ្នាំ ៨.ឈ្មោះ [redacted] មិថុនា ហៅ ងយ ភេទប្រុស អាយុ២២ឆ្នាំ និង ៩.ឈ្មោះ [redacted] សាន់ ភេទប្រុស អាយុ១៩ឆ្នាំ នៅខណៈដែលក្រុមជនសង្ស័យបានធ្វើសកម្មភាពដេញស្នាក់កាប់ទៅលើជនរងគ្រោះឈ្មោះ [redacted] ស៊ីមុិច ភេទប្រុស អាយុ៣៦ឆ្នាំ បណ្តាលឱ្យរងរបួសត្រង់កំភួនដៃ និងក្បាលពីក្រោយហូរឈាម និងកាប់ទៅលើឈ្មោះ [redacted] ស៊ីម៉ើល ភេទប្រុស អាយុ៣៤ឆ្នាំ បណ្តាលឱ្យរងរបួសត្រង់កញ្ចឹងក និងស្មាខាងឆ្វេងហូរឈាម ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២៥ អ.យ.ក/២០២២ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពត ។

-បានឃើញ ដីកាសន្និដ្ឋានស្តាពរលេខ ២១១ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពត ។

-បានឃើញ ដីកាដំណោះស្រាយដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥០៦/២២ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពត ។

ឆាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted]ចាន់រ៉ាត់ បានឆ្លើយនាពេលសវនាការថា: ខ្លួនពុំទទួលស្គាល់អង្គហេតុនិងបទចោទប្រកាន់ទេ ។ នៅចៅក្រមស៊ើបសួរខ្លួនទទួលស្គាល់ចម្លើយរបស់ខ្លួន ។ នៅនគរបាលខ្លួនមិនទទួលស្គាល់ទេ ដោយសារនគរបាលបានវាយបង្ខំខ្លួន ។ កាលពីថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០២២ ខ្លួនពិតជាយកដាវពីឈ្មោះ [redacted]រិទ្ធី ទៅកាប់ជនរងគ្រោះមែន ។ ឈ្មោះ [redacted] រតនៈ ជាអ្នកបញ្ជាឱ្យខ្លួនកាប់ ។ ឈ្មោះ [redacted]រិទ្ធី បានយកជំពាមបាញ់ជនរងគ្រោះ ។ ខ្លួនកាប់លើជនរងគ្រោះម្នាក់មួយដាវ ជនរងគ្រោះម្នាក់កាប់ត្រូវចំខ្នងឈ្មោះ [redacted]រតនៈ ជាអ្នកដឹកខ្លួន ។ ឈ្មោះ [redacted]លិ ឈ្មោះ [redacted] វន្នី ឈ្មោះ [redacted] មិថុនា និងឈ្មោះ [redacted] សាន់ មិនដឹងទេ ព្រោះមិនបានចូលរួម ។ មូលហេតុដែលខ្លួនកាប់ដោយសារឈ្មោះ [redacted] រតនៈ ជាអ្នកបញ្ជាឱ្យខ្លួនកាប់ ព្រោះជនរងគ្រោះទាំងពីរនេះធ្លាប់មានទំនាស់ជាមួយគ្នា ។ ដាវនេះជារបស់ [redacted]រិទ្ធី នៅកញ្ចុះ មិនមែនដាវរបស់ [redacted] វុទ្ធី ទេ ។ ពេលបំរុងកាប់នោះឈ្មោះ [redacted] រតនៈ ជាអ្នកសួររកដាវ ដើម្បីឱ្យខ្លួនកាប់ជនរងគ្រោះ ។ អ្នកដែលមានទំនាស់ជាមួយជនរងគ្រោះគឺឈ្មោះ [redacted]រតនៈ ។ ពេលកើតហេតុខ្លួនមានគ្នា ០៤នាក់ គឺខ្លួន ហើយឈ្មោះ [redacted]ទ្ធី ឈ្មោះ [redacted]រ៉ែន និងឈ្មោះ [redacted] រតនៈ ជិះម៉ូតូចំនួន០២គ្រឿង មួយគ្រឿងជិះគ្នា០២នាក់ ខ្លួនជិះជាមួយ [redacted] រតនៈ ចំណែកឯ [redacted]រិទ្ធី និងឈ្មោះ [redacted]រ៉ែន ជិះជាមួយគ្នា ។ ដាវនេះឈ្មោះ [redacted]រិទ្ធី ហៅស្វា ជាអ្នកឱ្យខ្លួន ចម្លើយនេះពិតប្រាកដ ចម្លើយពីមុនមិនពិតទេ ។ ចម្លើយខ្លួនទទួលស្គាល់ថាជិះម៉ូតូ០២គ្រឿង មានគ្នា០៤នាក់ ដូចការបញ្ជាក់ខាងលើ ។ ដាវនេះប្រវែងកន្លះម៉ែត្រ មុនពេលកើតហេតុមិនបានទៅលេងបាល់ទះទេ ពេលជិះមកជនរងគ្រោះមិនបានឌឺដងដាក់ខ្លួនទេ ។

-ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ហៅ ខ្វី បានឆ្លើយនាពេលសវនាការថា:កាលពីថ្ងៃទី ០៥ ខែកុម្ភៈ

ឆ្នាំ២០២២ ខ្លួនមិនបានចូលរួមកាប់ជនរងគ្រោះទេ ព្រោះពេលកើតហេតុខ្លួននៅផ្ទះ ។ ចម្លើយខ្លួននៅនគរបាល និងនៅចៅក្រមស៊ើបសួរខ្លួនមិនទទួលស្គាល់ទេ ។ ចម្លើយនៅនគរបាលគេវាយដំខ្លួន ខ្លាំងពេកគេវាយខ្លួនឱ្យឆ្លើយ ។ ចម្លើយនៅចៅក្រមស៊ើបសួរគេមិនបានវាយខ្លួនទេ ខ្លួនទទួលស្គាល់ ខ្លួនឆ្លើយតែពីរបីម៉ាត់ថាខ្លួនមិនបានកាប់គេទេ ។ នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ ២០២២ សមត្ថកិច្ចបានចាប់ខ្លួន ពេលខ្លួនមកដល់ផ្ទះឃើញមានជាវ មិនដឹងអ្នកយកមកទុកទេ ។ ខ្លួនទៅដើរលេងទាត់បាល់ជាមួយឈ្មោះ[redacted]លិ និង វ៉ែលវន្នី នៅម៉ោង ០២រសៀល ខ្លួនមិនដឹងគេមកយកជាវទេ ។ ពេលត្រឡប់មកវិញមានគ្នា០៣នាក់ដដែល ។ ពេលកើតហេតុខ្លួនបានជិះម៉ូតូ០៣នាក់ ខ្លួនជាអ្នកឌុបឈ្មោះ[redacted]លិ និងឈ្មោះ[redacted]វន្នី ពុំមានកាន់អ្វីទេ ។ ពេលកើតហេតុនោះ ខ្លួនមិនបានដឹងថាអ្នកណាកាប់លើជនរងគ្រោះទេ ។ ខ្លួនមិនដឹងថាអ្នកណាទៅយកជាវទេ ។ ពេលចេញមកវិញមានគ្នា០៩ នាក់មែន តែខ្លួនមិនបានចូលរួមកាប់ទេ ។

-ជនជាប់ចោទឈ្មោះ [redacted]វិទ្ធី ហៅ ស្វា បានឆ្លើយនាពេលសវនាការថា: នៅថ្ងៃកើតហេតុខ្លួននៅគ្នា ០២នាក់ជាមួយឈ្មោះ[redacted]រ៉ែន ។ ខ្លួនមិនបានយកដំពាមកៅស៊ូបាញ់ជនរងគ្រោះទេ ហើយខ្លួនមិនបានយកជាវពីផ្ទះរបស់[redacted]វុទ្ធី ទេ ។ ខ្លួនត្រូវបានគេទូរស័ព្ទឱ្យទៅលេងបាល់ទះ ហើយបានជួបនឹងឈ្មោះ[redacted]ចាន់រ៉ាត់ ។ សមត្ថកិច្ចបានឃាត់ខ្លួន នៅស្រុកឈូក ពេលយប់ រំលងពីរទៅបីថ្ងៃ ។ នៅពេលមើលគេលេងបាល់ទាត់រួចហើយទើបមើលបាល់ទះ ។ ខ្លួនមិនបានឃើញឈ្មោះ[redacted]វុទ្ធី នេះទេ ម្នាក់នេះខ្លួនមិនធ្លាប់ស្គាល់ទេ ។ ខ្លួនមិនបានឃើញជាវទេ ក្រៅពីឈ្មោះ[redacted]រ៉ែន គ្មានអ្នកណាទៅជាមួយខ្លួនទេ ខ្លួនមិនស្គាល់ឈ្មោះ[redacted]មិថុនា ទេ ខ្លួនធ្លាប់ឃើញគាត់ពីមុននៅកន្លែងលេងបាល់ ។ ឈ្មោះ[redacted]វុទ្ធី នៅថ្ងៃកើតហេតុ មិនឃើញទេ ។ ឈ្មោះ[redacted]លិ ឈ្មោះ[redacted]វន្នី ឈ្មោះ[redacted]សាន់ ឈ្មោះ[redacted]មិថុនា ខ្លួនមិនធ្លាប់ស្គាល់ទេ ។ ឈ្មោះ[redacted]រតនៈ មិនមានទំនាស់ជាមួយជនរងគ្រោះទេ ។

-ជនជាប់ចោទឈ្មោះ[redacted]រ៉ែន បានឆ្លើយនាពេលសវនាការថា: ខ្លួនមិនទទួលស្គាល់អង្គហេតុ និងបទចោទប្រកាន់ទេ ។ កាលពីថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០២២ ខ្លួនមិនបានចូលរួមកាប់ជនរងគ្រោះទេ ។ ខ្លួនទៅមើលបាល់ជាមួយ បូ វិទ្ធី នៅម៉ោង ១១ ថ្ងៃត្រង់ វាមកយកខ្លួននៅម៉ោង ០៩ ព្រឹក ។ ខ្លួនបានជួបឈ្មោះ[redacted]ចាន់រ៉ាត់ ខ្លួនមិនស្គាល់ជនរងគ្រោះទាំងពីរនាក់នោះទេ ។ ថ្ងៃកើតហេតុខ្លួនបានជួបនឹងឈ្មោះ[redacted]ចាន់រ៉ាត់ ម្តងនៅកន្លែងបាល់ទាត់ ខ្លួនមិនស្គាល់ពួកគេទេ ។ ខ្លួនជិះម៉ូតូទៅកញ្ចុះមានរូបខ្លួន ឈ្មោះ[redacted]វិទ្ធី ឈ្មោះ[redacted]រ៉ែន និងម្នាក់ទៀតខ្លួនមិនស្គាល់ឈ្មោះទេ ។ នៅថ្ងៃកើតហេតុខ្លួនជិះម៉ូតូ តែពីរនាក់ឈ្មោះ[redacted]រ៉ែន ។ ខ្លួនមិនធ្លាប់ស្គាល់ឈ្មោះ[redacted]រតនៈ ទេ ។

-ជនជាប់ចោទឈ្មោះ[redacted]លិ បានឆ្លើយនាពេលសវនាការថា: ខ្លួនជិះម៉ូតូមានគ្នាបី នាក់ រូបខ្លួន ឈ្មោះ[redacted]វុទ្ធី និងឈ្មោះ[redacted]វន្នី ។ ឈ្មោះ[redacted]រតនៈ ឌុប ឈ្មោះ[redacted]ចាន់រ៉ាត់ និងឈ្មោះ[redacted]វិទ្ធី ឌុប ឈ្មោះ[redacted]រ៉ែន ។ ពេលចេញមកមានគ្នា០៤នាក់ ជិះក្រោយនេះដែរ ។ ឈ្មោះ[redacted]ចាន់រ៉ាត់ ពិតជាបានកាប់ជនរងគ្រោះទាំងពីរនាក់នោះមែន ។ ខ្លួនស្គាល់ឈ្មោះ[redacted]រតនៈ គាត់មិនមានទំនាស់អ្វីជាមួយជនរងគ្រោះទាំងពីរនាក់នេះទេ ។

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted]រតនៈ ហៅ យី បានឆ្លើយនៅជំណាក់កាលចៅក្រមស៊ើបសួរថា: ចម្លើយដែលខ្លួនបានឆ្លើយនៅចំពោះមុខសមត្ថកិច្ច កាលពីថ្ងៃទី០៦ ខែ កុម្ភៈឆ្នាំ ២០២២ វេលាម៉ោង ១០ព្រឹក ខ្លួនសូមរក្សាទុកជាបានការដដែល និងចម្លើយដែលខ្លួនបានឆ្លើយនៅចំពោះមុខតំណាងអយ្យការអមសាលាដំបូងខេត្តកំពត ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង១០ និង៥០ នាទីព្រឹក លោកក្រឡាបញ្ជីបានអានឱ្យខ្លួនស្តាប់ ខ្លួនរក្សាទុកជាបានការ ។ នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ ២០២២ វេលាម៉ោងប្រហែល ០៣ រសៀល ឈ្មោះ ចាន់ រ៉ាត់ ភេទប្រុស អាយុ២៤ឆ្នាំ បានមកបបួលខ្លួនទៅមើលគេប្រកួតបាល់ទាត់នៅសាលាវិទ្យាល័យជងទង់ ពេលទៅដល់ពួកខ្លួន បានមើលមួយសន្ទុះ ក៏បាននាំគ្នាជិះត្រឡប់ទៅផ្ទះវិញ ដោយសារនៅពេលអង្គុយមើលគេនោះ ខ្លួនឃើញមានក្មេងស្មាវនិយាយឌឺដងជាមួយឈ្មោះ[redacted]រ៉ាត់ ។ ពេលជិះចេញក្រៅសាលាវិញ ខ្លួនជាអ្នកឌុបឈ្មោះ[redacted]រ៉ាត់ បានចម្ងាយ

ប្រហែល ០២គីឡូម៉ែត្រ ឃើញមនុស្សប្រុសពីរនាក់(មិនស្គាល់ឈ្មោះ) ជិះម៉ូតូហុងដាឌ្រីមពណ៌ខ្មៅមិនចាំផ្លាកលេខ ពេលខ្លួនបម្រុងជិះវ៉ា ស្រាប់តែឈ្មោះ [redacted] រ៉ាត់ ទាញកាំបិត (មិនដឹងទុកនៅកន្លែងណា) កាប់លើមនុស្សប្រុសទាំងពីរនាក់ ដោយខ្លួនពុំបានដឹងអ្វីទាំងអស់ ។ ពេលឈ្មោះ [redacted] រ៉ាត់ កាប់ជនរងគ្រោះទាំងពីរនាក់រួចហើយ ក៏បានជូរម៉ូតូ ជិះម៉ូតូម៉ាកហុងដាឌ្រីមសេ១២៥ សេរី២០២១ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ។ ចំណែកខ្លួនក៏បានជិះម៉ូតូត្រឡប់មកផ្ទះវិញ ជាមួយឈ្មោះ លិ ភេទប្រុស អាយុ១៨ឆ្នាំ ។ នៅពេលដែលខ្លួនទៅមើលគេប្រកួតបាល់ទាត់ ជនរងគ្រោះមិនបានទៅមើលទេ ហើយក៏មិនដឹងរឿងអ្វីដែរ ។ សំណូមពរសូមឱ្យតុលាការមេត្តាដាក់ខ្លួនក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងសុំឱ្យខ្លួនបានត្រឡប់ទៅផ្ទះវិញផង ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ ហើយសព្វថ្ងៃខ្លួនក៏ជានិស្សិតកំពុងសិក្សានៅរាជធានីភ្នំពេញផងដែរ ។ ដោយខ្លួនមានអាស័យដ្ឋានពិតប្រាកដនៅភូមិសត្វពង ឃុំសត្វពង ស្រុកទឹកឈូ ខេត្តកំពត ។

សំណូមពររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានថ្លែងការណ៍ថា: ស្នើសុំឱ្យកូនក្តីរបស់ខ្លួនដាក់ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយហេតុថាកូនក្តីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ។ កូនក្តីខ្លួនគ្រាន់តែឌុប ឈ្មោះ [redacted] រ៉ាត់ ដែលជាជនដៃដល់ ប៉ុណ្ណោះ ។ ហើយកូនក្តីខ្លួនមិនដឹងថាជនដៃដល់មានកាំបិទលាក់នៅក្នុងខ្លួនឡើយ ។ ហើយក៏មិនដឹងថាឈ្មោះ [redacted] រ៉ាត់ និងជនរងគ្រោះមានទំនាស់អ្វីនឹងគ្នាដែរ ដែលសបញ្ជាក់ឱ្យឃើញកូនក្តីខ្លួនពុំមានចេតនាប្រព្រឹត្តបទល្មើសឡើយ ដោយយោងតាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌចែងថា: ពុំមានចេតនាប្រព្រឹត្តបទល្មើសទេ បើសិនគ្មានចេតនាប្រព្រឹត្ត ។ និងយោងតាមសេចក្តីណែនាំលេខ ០៣ កយ.សណន/២២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ របស់ក្រសួងយុត្តិធម៌បានកំណត់ថា យោងតាមស្មារតីមាត្រា ២០៣ ជាគោលការណ៍ជនត្រូវចោទត្រូវមានសេរីភាព ហើយការឃុំខ្លួនបណ្តោះអាសន្នធ្វើឡើងតែក្នុងករណីពិសេសតែប៉ុណ្ណោះ ទទឹមនឹងនេះក្រមនីតិវិធីបានចែងផងដែរ អំពីរការឱ្យស្ថិតក្រោមត្រួតពិនិត្យតាមផ្លូវតុលាការ ដែលជាវិធានការណ៍ និរន្តរាយមួយដែលយកទៅប្រើជានាជាល់ដំណើរការនីតិវិធីជំនួសឱ្យការឃុំខ្លួនបណ្តោះអាសន្ន ។ ចៅក្រមស៊ើបសួរគប្បីយកចិត្តទុកដាក់លើស្មារតីមាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជាពិសេសស្មារតីនៃគោលការណ៍សេរីភាពជាចំបង និងគោលការណ៍សន្មតជាមុនទុកជាគ្មានទោស ។ ការឃុំខ្លួនបណ្តោះអាសន្នគប្បីត្រូវប្រើសម្រាប់បទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលមានភាពស្មុកស្មាញ និងធ្ងន់ធ្ងរ ហើយក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌជាពិសេស ក្នុងករណីដែលឃុំខ្លួនជាបណ្តោះអាសន្ននោះ គឺជាមធ្យោបាយតែមួយគត់ លើការស៊ើបសួរតែប៉ុណ្ណោះ ។ លើកទឹកចិត្តឱ្យចៅក្រមស៊ើបសួរសម្រេចជ្រើសរើសយកការដាក់ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងជាវិធាននិរន្តរាយជំនួយឱ្យការឃុំខ្លួនបណ្តោះអាសន្ន ដើម្បីដំណើរនៃការស៊ើបសួរ ស្របតាមមាត្រា ២២៣ ដល់មាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជាពិសេសបទមជ្ឈិម ដែលមានភាពស្មុកស្មាញនិងធ្ងន់ធ្ងរ ។ នៅពេលដែលកូនក្តីខ្លួនដាក់ស្ថិតក្រោមការត្រួតពិនិត្យ កូនក្តីខ្លួនសន្យាថានិងធ្វើតាមបញ្ជារបស់អាជ្ញាធរ ឬតុលាការ និងសហការជាមួយសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ដោយមិនគេចវេស ឬបង្កការរាំងស្ទះដល់នីតិវិធីរបស់តុលាការឡើយ ។ ហើយកូនក្តីខ្លួនទៀតសោតពុំបានប្រព្រឹត្តបទល្មើសពីមុនទេ ដូច្នោះមិនអាចឈានទៅដល់ការធ្វើសកម្មភាពផ្សេងដូចជា គំរាមសាក្សី ឬជនរងគ្រោះ ហើយកូនក្តីខ្លួនក៏គ្មានលទ្ធភាពបំផ្លាញភស្តុតាង ឬតំរុយឡើយ ដូច្នោះហើយទើបខ្លួនស្នើសុំឱ្យចៅក្រមស៊ើបសួរដាក់កូនក្តីខ្លួននៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយក្តីអនុគ្រោះ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីម៉ើល បានឆ្លើយនាពេលសវនាការថា: ថ្ងៃកើតហេតុនោះខ្លួនមិនមានទំនាស់ជាមួយជនជាប់ចោទទេ ខ្លួនស្គាល់តែឈ្មោះ ចាន់រ៉ាត់ ព្រោះនៅផ្ទះក្បែរគ្នា ហើយឈ្មោះ ចាន់រ៉ាត់ ជាអ្នកកាប់ខ្លួនមួយដាវ និងកាប់បងប្រុសរបស់ខ្លួនមួយដាវ ។ នៅថ្ងៃកើតហេតុមានម៉ូតូចំនួន០៤គ្រឿង និងមានគ្នាចំនួន០៩នាក់ខ្លួនស្គាល់តែឈ្មោះ ចាន់រ៉ាត់ ទេ ។ ខ្លួនមិនមានទំនាស់ជាមួយឈ្មោះ [redacted] រតនៈទេ ។ ក្នុងរឿងនេះខ្លួនសុំឱ្យតុលាការចាត់ការតាមច្បាប់ចុះ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីមុិច បានឆ្លើយនាពេលសវនាការថា: ថ្ងៃកើតហេតុនោះអ្នក

កាប់ខ្លួនមិនដឹងអ្នកណាទេ តែប្អូនរបស់ខ្លួនប្រាប់ថាឈ្មោះ ចាន់រ៉ាត់ ជាអ្នកកាប់ ។ ខ្លួនសុំឱ្យតុលាការសម្រេចតាមច្បាប់ចុះ ដោយមិនទាមទារអ្វីទេ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីសវនាការមកឃើញថាឈ្មោះ [redacted] ចាន់រ៉ាត់ ជាអ្នកកាប់ផ្ទាល់ ជនជាប់ចោទទាំង០៤នាក់ បានឆ្លើយបដិសេធពីបទចោទប្រកាន់ ប៉ុន្តែនៅចៅក្រមស៊ើបសួរបានឆ្លើយសារភាពអស់ហើយ ដូច្នេះសុំតម្កល់ដីកាសន្និដ្ឋានស្តាពរទុកនៅដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រតន: បានសន្និដ្ឋានថា: ក្រោយពីបានសាកសួរមកឃើញថា តាមអង្គហេតុគឺជនជាប់ចោទឈ្មោះ [redacted] ចាន់រ៉ាត់ ជាអ្នកកាប់ផ្ទាល់ កូនក្តីខ្លួនជាអ្នកបើកម៉ូតូ កូនក្តីខ្លួនមិនពាក់ពន្ធ័ទេ ។ ព្រោះគាត់ឆ្លើយដាក់កូនក្តីខ្លួនថាកូនក្តីខ្លួនជាអ្នកបញ្ជា និងថាកូនក្តីខ្លួនមានទំនាស់ជាមួយជនរងគ្រោះ តែជនរងគ្រោះថាមិនមានទំនាស់ជាមួយឈ្មោះ [redacted] រតន: ទេ ផ្អែកតាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ ពុំមានបទល្មើសទេ បើគ្មានចេតនាប្រព្រឹត្ត ។

-ជនជាប់ចោទឈ្មោះ [redacted] រ៉ុទ្ធី ហៅ ខ្ចី បាននិយាយសំដីចុងក្រោយថា: ខ្លួនសុំឱ្យតុលាការ ជួយរកយុត្តិធម៌ដល់រូបខ្លួនផង ។

-ជនជាប់ចោទឈ្មោះ [redacted]ទ្ធី ហៅ ស្វា បាននិយាយសំដីចុងក្រោយថា: ខ្លួនសុំឱ្យតុលាការ ជួយរកយុត្តិធម៌ដល់រូបខ្លួនផង ។

-ជនជាប់ចោទឈ្មោ[redacted]រ៉ែន បាននិយាយសំដីចុងក្រោយថា: ខ្លួនសុំឱ្យតុលាការ ជួយរកយុត្តិធម៌ដល់រូបខ្លួនផង ។

-ជនជាប់ចោទឈ្មោះ[redacted] ចាន់រ៉ាត់ បាននិយាយសំដីចុងក្រោយថា: ខ្លួនសុំឱ្យតុលាការបន្ធូរបន្ថយទោសដល់រូបខ្លួនផង ។

-ជនជាប់ចោទឈ្មោះ[redacted] លិ បាននិយាយសំដីចុងក្រោយថា: ខ្លួនសុំឱ្យតុលាការ ជួយរកយុត្តិធម៌ដល់រូបខ្លួនផង ។

<u>សំអាងហេតុ</u>

-ក្រោយពីបានស្តាប់ចម្លើយនិងអំណានចម្លើយជនជាប់ចោទ
-ក្រោយពីបានស្តាប់ចម្លើយជនរងគ្រោះនិងជាដើមបណ្តឹងរដ្ឋប្បវេណី
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ
-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
-ក្រោយពីបានពិនិត្យកសុតាង
-ក្រោយពីបានពិនិត្យ ពិចារណា លើសំណុំរឿងចប់សព្វគ្រប់ យើញថា:

១-ជនជាប់ចោទឈ្មោះ [redacted] រ៉ុទ្ធី ហៅ ខ្ចី , ឈ្មោះ [redacted] រតន: ហៅ យី , ឈ្មោះ [redacted]ទ្ធី ហៅ ស្វា ឈ្មោះ [redacted]រ៉ែន, ឈ្មោះ [redacted] រិន្ទី, ឈ្មោះ [redacted] ចាន់រ៉ាត់, ឈ្មោះ[redacted] លិ, ឈ្មោ[redacted] មិថុនា ហៅ ងយ, ឈ្មោះ [redacted]សាន់ ត្រូវបានចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពត បញ្ជូនមកជំនុំជម្រះពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស (ប្រើដាវ) ប្រព្រឹត្តនៅ ភូមិត្រពាំងតាមាល ឃុំដំណាក់សុក្រំ ស្រុកដងទង់ ខេត្តកំពត កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រមទណ្ឌ ។

២-ជនជាប់ចោទឈ្មោះ [redacted] រ៉ុទ្ធី ហៅ ខ្ចី ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ [redacted] រតន: ហៅ យី ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ [redacted]ទ្ធី ហៅ អាស្វា ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ [redacted] រ៉ែន ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ [redacted] រិន្ទី ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ, ឈ្មោ[redacted] ចាន់រ៉ាត់ ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ[redacted] លិ ភេទប្រុស កើតថ្ងៃទី០៥ ខែ

វិច្ឆិកា ឆ្នាំ២០០៣ (អាយុ១៩ឆ្នាំ) ជនជាតិខ្មែរ, ឈ្មោះ [redacted] មិថុនា ភេទប្រុស កើតថ្ងៃទី១២ ខែធ្នូ ឆ្នាំ ២០០០ (អាយុ១៩ឆ្នាំ) ជនជាតិខ្មែរ, ឈ្មោះ [redacted] សាន់ ភេទប្រុស កើតថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៣ ជនជាតិខ្មែរ ជានីតិជនដែលអាចទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន ហើយពុំមានសញ្ញាណាមួយដែលនាំឱ្យមានការសង្ស័យអំពីបញ្ហាស្មារតីឡើយ ដូចនេះជននេះប្រាកដជាយល់ដឹងថា អំពើរបស់ខ្លួនពិតជាប៉ះពាល់ធ្ងន់ធ្ងរដល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម ។

៣-ក្រោយពីបានពិនិត្យកសុតាងចម្លើយរបស់ជនជាប់ចោទ ចម្លើយរបស់ជនរងគ្រោះទាំងពីរនាក់នៅគ្រប់ដំណាក់កាលនៃនីតិវិធី ព្រមទាំងកសុតាងឯកសារ និងរូបថតរងរបួសរបស់ជនរងគ្រោះផងនោះ យើញថា៖

កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២ ស្ថិតនៅភូមិ ត្រពាំងតាមាល ឃុំដំណាក់សុក្រំ ស្រុកដងទង់ ខេត្តកំពត មានករណី ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ដោយយកកាប់ជនរងគ្រោះឈ្មោះ [redacted] សុីមុិច និងឈ្មោះ [redacted] សុីមើល បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ចាន់រ៉ាត់ ភេទប្រុស អាយុ២៥ ឆ្នាំ និងឈ្មោះ [redacted] រតនៈ ហៅ យី ភេទប្រុស អាយុ២១ឆ្នាំ ប្រាកដមែន ដោយជនជាប់ចោទឈ្មោះ [redacted] រតនៈ ជាអ្នកឧបនិងឈ្មោះ [redacted] ចាន់រ៉ាត់ ជាអ្នកជិះខាងក្រោយបានយកដាវកាប់ទៅលើជនរងគ្រោះទាំងពីរខាងលើ បណ្តាលឱ្យជនរងគ្រោះឈ្មោះ [redacted] សុីមុិច ភេទប្រុស អាយុ៣៦ឆ្នាំ បណ្តាលឱ្យរងរបួសត្រង់កំភួនដៃ និងក្បាលពីក្រោយហូរឈាម និងកាប់ទៅលើឈ្មោះ [redacted] សុីមើល ភេទប្រុស អាយុ៣៨ឆ្នាំ បណ្តាលឱ្យរងរបួសត្រង់កញ្ចឹងក និងស្មាខាងឆ្វេងហូរឈាម ។

ដោយឡែកជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ហៅ ខ្វី នៅក្នុងអង្គហេតុបុគ្គលនេះធ្លាប់បានទទួលស្គាល់ថាបានទុកដាវនៅមុនពេលកើតហេតុ ហើយឈ្មោះ ចាន់រ៉ាត់ និងឈ្មោះ សាន់ ជាអ្នកទៅយកដាវនៅមុនពេលកើតហេតុ ហើយជននេះក៏មានវត្តមាននៅពេលដែលបង្កអំពើហិង្សាទៅលើជនរងគ្រោះផងដែរ ។ មួយវិញទៀតចំពោះជនជាប់ចោទឈ្មោះ [redacted] សាន់ ឃើញថាផ្ទៃកតាមការអះអាងរបស់ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី នៅដំណាក់កាលស៊ើបសួរ បញ្ជាក់ច្បាស់ថានៅមុនពេលកើតហេតុឈ្មោះនេះបានទៅយកដាវពីផ្ទះរបស់ខ្លួន ហើយឈ្មោះ [redacted] សាន់ ក៏បានចូលរួមវត្តមាននៅពេលដែលឈ្មោះ [redacted] រ៉ាត់ កាប់ទៅលើជនរងគ្រោះផងដែរ ដែលវាមានភាពស៊ីសង្វាក់ទៅនឹងចម្លើយជនជាប់ចោទដទៃទៀតដែលអះអាងថានៅពេលកើតហេតុពួកខ្លួនមានគ្នា ០៩នាក់បានជិះម៉ូតូទៅជាមួយគ្នា ។ ដូច្នេះតុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted] សាន់ មានពាក់ព័ន្ធនឹងករណីសមគំនិតក្នុងអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដែលបង្កឡើយដោយជនជាប់ចោទឈ្មោះ ចាន់រ៉ាត់ និងឈ្មោះ [redacted] រតនៈ គប្បីតុលាការសម្រេចកែប្រែបទចោទប្រកាន់តាមច្បាប់ ។

ចំណែកជនជាប់ចោទឈ្មោះ [redacted] រិទ្ធី ហៅ ស្វា ភេទប្រុស អាយុ២១ឆ្នាំ ថ្វីត្បិតតែនាពេលសវនាការជនជាប់ចោទឈ្មោះ ចាន់រ៉ាត់ បានឆ្លើយថាឈ្មោះនេះបានប្រគល់ដាវឱ្យខ្លួន ប៉ុន្តែចម្លើយនេះផ្ទុយទៅនឹងចម្លើយដែលមាននៅក្នុងគ្រប់ដំណាក់កាលនីតិវិធីដែលជនជាប់ចោទផ្សេងទៀតបានអះអាង ក៏ដូចជាចម្លើយរបស់ឈ្មោះ [redacted] ចាន់រ៉ាត់ ដែលឆ្លើយនៅដំណាក់កាលស៊ើបសួរថា ដាវជារបស់ឈ្មោះ យី ហើយឈ្មោះ យី នៅពេលកើតហេតុជាអ្នកស្រែកឱ្យខ្លួនកាប់លើជនរងគ្រោះ ដូច្នេះតុលាការយល់ឃើញថាពុំមានកសុតាងបញ្ជាក់ជាក់លាក់លើពិរុទ្ធភាពរបស់ជននេះឡើយ ។ រីឯជនជាប់ចោទឈ្មោះ អ៊ុក រ៉ែន ភេទប្រុស អាយុ២២ឆ្នាំ, ឈ្មោះ [redacted] វន្នី ភេទប្រុស អាយុ១៩ឆ្នាំ, ឈ្មោះ [redacted] លិ ភេទប្រុស អាយុ១៩ឆ្នាំ, ឈ្មោះ [redacted] មិថុនា ហៅ ងយ ភេទប្រុស អាយុ២២ឆ្នាំ ពិតជាបានចូលរួមដំណើរជាមួយជនជាប់ចោទទាំងអស់ខាងលើ ប៉ុន្តែមិនមានកសុតាងបញ្ជាក់ថាជនជាប់ចោទទាំងបួននាក់ បានចូលរួមសកម្មភាពប្រើហិង្សាដោយចេតនាមានស្ថានទម្ងន់ ដូចការបទចោទប្រកាន់ឡើយ ។ ដូច្នេះគប្បីតុលាការសម្រេចឱ្យជនជាប់ចោទរួចខ្លួនពីបទចោទប្រកាន់ស្របតាមបញ្ញត្តិមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៤-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីសវនាការមកឃើញថា ជនជាប់ចោទបានធ្លើយសារភាព មានភាពស៊ីចង្វាក់ទៅនឹងភស្តុតាង ហេតុនេះសុំតម្កល់ដីកាសន្និដ្ឋានស្តាពរទុកនៅដដែល និងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ គប្បីតុលាការពិចារណា ។

៥-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រតនៈ បានសន្និដ្ឋានថា: ក្រោយពីបានសាកសួរមកឃើញថា តាមអង្គហេតុគឺជនជាប់ចោទឈ្មោះ [redacted] ចាន់រ៉ាត់ ជាអ្នកកាប់ផ្ទាល់ កូនក្តីខ្លួនជាអ្នកបើកម៉ូតូ កូនក្តីខ្លួនមិនពាក់ពន្ធ័ទេ ។ ព្រោះគាត់ធ្លើយដាក់កូនក្តីខ្លួនថាកូនក្តីខ្លួនជាអ្នកបញ្ជា និងថាកូនក្តីខ្លួនមានទំនាស់ជាមួយជនរងគ្រោះ តែជនរងគ្រោះថាមិនមានទំនាស់ជាមួយឈ្មោះ [redacted] រតនៈ ទេ ផ្អែកតាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ ពុំមានបទល្មើសទេបើគ្មានចេតនាប្រព្រឹត្ត ។ ចំណុចនេះ គប្បីតុលាការពិចារណាតាមអង្គហេតុជាក់ស្តែង ។

៦-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ ៖

-ឈ្មោះ [redacted] ចាន់រ៉ាត់ ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] រតនៈ ហៅ យី ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស (ប្រើដាវ) ប្រព្រឹត្តនៅភូមិត្រពាំងតាមាល ឃុំដំណាក់សុក្រំ ស្រុកដងទង់ ខេត្តកំពត កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

-ឈ្មោះ [redacted] វុទ្ធី ហៅ ខ្វី ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] សាន់ ភេទប្រុស កើតថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៣ ជនជាតិខ្មែរ ពីបទ **សមគំនិតក្នុងអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** (ប្រើដាវ) ប្រព្រឹត្តនៅ ភូមិត្រពាំងតាមាល ឃុំដំណាក់សុក្រំ ស្រុកដងទង់ ខេត្តកំពត កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២៩ និងមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

៧-គ្មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] វិទ្ធី ហៅ **អាស្វា** ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ [redacted] រ៉ែន ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ [redacted] វន្នី ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ [redacted] លិ ភេទប្រុស កើតថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៣ អាយុ១៩ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ [redacted] មិថុនា ភេទប្រុស កើតថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០០ អាយុ១៩ឆ្នាំ ជនជាតិខ្មែរ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស (ប្រើដាវ) ប្រព្រឹត្តនៅ ភូមិត្រពាំងតាមាល ឃុំដំណាក់សុក្រំ ស្រុកដងទង់ ខេត្តកំពត កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

៨-ជនជាប់ចោទឈ្មោះ [redacted] ចាន់រ៉ាត់ ត្រូវបានចៅក្រមស៊ើបសួរឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១០៣/២២ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២ ។ ជននេះជាជនដៃដល់ក្នុងការប្រព្រឹត្តអំពើហិង្សាមានស្ថានទម្ងន់ទោសទៅលើជនរងគ្រោះ ហើយជននេះក៏ធ្លាប់មានប្រវត្តិជាប់ពន្ធនាគារចំនួន០២ឆ្នាំពាក់ព័ន្ធនឹងករណីជួញដូរនិងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដូច្នេះគប្បីតុលាការពិចារណា និងសម្រេចផ្តន្ទាទោសតាមកំណត់ច្បាប់ ។

៩-ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ហៅ ខ្វី ត្រូវបានចៅក្រមស៊ើបសួរឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៨៨/២២ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ និងជនជាប់ចោទឈ្មោះ [redacted] សាន់ ត្រូវបានចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ១០៨/២២ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ ដើម្បីយកជននេះមក បង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរតាមនីតិវិធី ។ ជនទាំងនេះមិនធ្លាប់មានប្រវត្តិប្រព្រឹត្តបទល្មើសពីមុនមក ហើយជនជាប់ចោទទាំងពីរមានពិរុទ្ធភាពក្នុងអំពើសមគំនិតក្នុងបទមជ្ឈិម ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] រតនៈ ហៅ យី ត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩០/២២ ចុះថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០២២ ហើយត្រូវបានដោះលែងឱ្យនៅក្រៅឃុំតាមដីកាបង្គាប់ឱ្យដោះលែងលេខ ៧៤/ ២២ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ ហើយជននេះមិនធ្លាប់មានប្រវត្តិប្រព្រឹត្តបទល្មើសពីមុន ។ ដូច្នេះ

គប្បីតុលាការពិចារណាផ្តល់ នូវការប្រកាសការព្យួរទោសស្របតាមមាត្រា១០៦ មាត្រា១០៧ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ ។

១០-ជនជាប់ចោទឈ្មោះ [redacted]រិន្ទ ឈ្មោះ[redacted]មិថុនា និងឈ្មោះ[redacted]សាន់ ត្រូវបានចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ដូច្នេះគប្បីតុលាការសម្រេចបញ្ឈប់ដីកាបង្គាប់ឱ្យចាប់ខ្លួនលើជនជាប់ចោទទាំងបីនាក់តាមនីតិវិធី ។

១១-ដើមបណ្តឹងរបៀវេណីឈ្មោះ[redacted] ស៊ីមុច និងឈ្មោះ[redacted] ស៊ីមើល ធ្លាប់ទទួលបានសំណងថ្លៃព្យាបាលរបួសពីភាគីជនជាប់ចោទ ហើយនៅពេលសវនាការ មិនបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាមទារសំណងអ្វីបន្ថែមឡើយ ដូច្នេះតុលាការនឹងមិនពិចារណាអំពីបញ្ហាសំណងរដ្ឋប្បវេណីឡើយ ។

១២-វត្ថុចាប់យក ដកហូតពីឈ្មោះ[redacted]រុទ្ធី ដូចមាននៅក្នុង កំណត់ហេតុដកហូត ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលស្រុកដងទង់ មាន **ទូរស័ព្ទ** ម៉ាក NOKIA (**អិនចុចពិល**) ពណ៌ខ្មៅ ចំនួន ០១គ្រឿង គប្បីតុលាការសម្រេចប្រគល់ឱ្យទៅ ម្ចាស់ដើមវិញ ដោយហេតុថាវត្ថុចាប់យកនេះមិនពាក់ព័ន្ធទៅនឹងបទល្មើសខាងលើឡើយ ។

<u>ហេតុដូច្នេះសម្រេច</u>

១-ឱ្យរួចខ្លួនពីបទចោទប្រកាន់លើជនជាប់ចោទ ៖

ក-ឈ្មោះ[redacted]រិទ្ធី ហៅ **អាស្វា** ភេទប្រុស អាយុ ២១ឆ្នាំ ជនជាតិខ្មែរ

ខ-ឈ្មោះ[redacted]រ៉ែន ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ

គ-ឈ្មោះ[redacted]រិន្ទី ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ

ឃ-ឈ្មោះ[redacted]លិ ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ

ង-ឈ្មោះ[redacted] មិថុនា ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ

ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅ ភូមិត្រពាំងតាមាល ឃុំដំណាក់សុក្រំ ស្រុកដងទង់ ខេត្តកំពត កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ ។

២-កែប្រែបទចោទប្រកាន់លើជនជាប់ចោទ ៖

ក-ឈ្មោះ[redacted]រុទ្ធី ហៅ **ខ្ចី** ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ

ខ-ឈ្មោះ[redacted]សាន់ ភេទប្រុស កើតឆ្នាំ២០០៣ ជនជាតិខ្មែរ

ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅ ភូមិត្រពាំងតាមាល ឃុំដំណាក់សុក្រំ ស្រុកដងទង់ ខេត្តកំពត កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ ទៅជាបទ **សមគំនិតក្នុងអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅ ភូមិត្រពាំងតាមាល ឃុំដំណាក់សុក្រំ ស្រុកដងទង់ ខេត្តកំពត កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២៩ និងមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ ។

៣-ផ្តន្ទាទោសលើជនជាប់ចោទ ៖

ក-ឈ្មោះ[redacted]ចាន់រ៉ាត់ ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ ជាក់ពន្ធនាគារចំនួន ០២(ពីរ)ឆ្នាំ ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅ ភូមិត្រពាំងតាមាល ឃុំដំណាក់សុក្រំ ស្រុកដងទង់ ខេត្តកំពត កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ ។

ខ-ឈ្មោះ[redacted] រតនៈ ហៅ យី ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ ជាក់ពន្ធនាគារចំនួន ០២(ពីរ)ឆ្នាំ ប៉ុន្តែទោសអនុវត្តក្នុងពន្ធនាគារកំណត់រយៈពេល ០៤(បួន)ខែ ២០(ម្ភៃ)ថ្ងៃ ទោសសល់ពីនេះត្រូវព្យួរ

ធម្មតា ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅ ភូមិត្រពាំងតាមាល ឃុំដំណាក់សុក្រំ ស្រុកដងទង់ ខេត្តកំពត កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២១៨ មាត្រា១០៦ មាត្រា១០៧ និងមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ ។

គ-ឈ្មោះ [redacted] វុទ្ធី ហៅ ខ្ចី ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ ជាក់ពន្ធនាគារចំនួន ០២(ពីរ) ឆ្នាំ ប៉ុន្តែទោសអនុវត្តក្នុងពន្ធនាគារកំណត់រយៈពេល ១១(ដប់មួយ)ខែ ទោសសល់ពីនេះត្រូវព្យួរធម្មតា ពីបទ សមគំនិតក្នុងអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅ ភូមិត្រពាំងតាមាល ឃុំដំណាក់សុក្រំ ស្រុកដងទង់ ខេត្តកំពត កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២៩ មាត្រា២១៨ មាត្រា១០៦ មាត្រា១០៧ និងមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ ។

ឃ-ឈ្មោះ [redacted] សាន់ ភេទប្រុស កើតឆ្នាំ២០០៣ ជនជាតិខ្មែរ ជាក់ពន្ធនាគារចំនួន ០២(ពីរ)ឆ្នាំ ប៉ុន្តែទោសនេះត្រូវព្យួរធម្មតា ពីបទ សមគំនិតក្នុងអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅ ភូមិត្រពាំងតាមាល ឃុំដំណាក់សុក្រំ ស្រុកដងទង់ ខេត្តកំពត កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២៩ មាត្រា២១៨ មាត្រា១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ។

៤-បញ្ឈប់ដីកាបង្គាប់ឱ្យចាប់ខ្លួន ៖

ក-លេខ ១០៨/២២ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពត លើឈ្មោះ [redacted] សាន់ ។

ខ-លេខ ១០៩/២២ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពត លើឈ្មោះ វ៉ែង មិថុនា ។

គ-លេខ ១១០/២២ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពត លើឈ្មោះ [redacted] វន្នី ។

៥-វត្ថុចាប់យក ដកហូតពីឈ្មោះ [redacted] វុទ្ធី ដូចមាននៅក្នុង កំណត់ហេតុដកហូត ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលស្រុកដងទង់ មាន **ទូរស័ព្ទ** ម៉ាក NOKIA (អិនចុចពិល) ពណ៌ខ្មៅ ចំនួន ០១គ្រឿង ត្រូវប្រគល់ឱ្យទៅម្ចាស់ដើមវិញ ។

-សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចាន់ារ៉ាត់, ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ហៅ ខ្ចី, ជនជាប់ចោទឈ្មោះ [redacted] រិទ្ធី ហៅ អាស្វា, ជនជាប់ចោទឈ្មោះ [redacted] រ៉ែន, ជនជាប់ចោទឈ្មោះ [redacted] លិ និងកំពាំងមុខជនជាប់ចោទឈ្មោះ [redacted] រតនៈ ហៅ យី, ជនជាប់ចោទឈ្មោះ [redacted] វន្នី, ជនជាប់ចោទឈ្មោះ [redacted] មិថុនា និងជនជាប់ចោទឈ្មោះ [redacted] សាន់ ។

-ទុកសិទ្ធិប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ **ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា: [redacted] ហត្ថលេខា និងត្រា: [redacted]

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]

“បានចម្លងត្រឹមត្រូវតាមច្បាប់ដើម”

ថ្ងៃពុធ ៦រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

កំពត, ថ្ងៃទី១៤ ខែ ធ្នូ ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]